**ជនបរទេស (Alien)**

ជនបរទេស សំដៅដល់ពលរដ្ឋនៃប្រទេសមួយ ដែលរស់នៅក្នុងប្រទេសមួយទៀត។ ពួកគេមិនមានសិទ្ធិពេញលេញដូចប្រជាពលរដ្ឋនៃប្រទេសដែលខ្លួនរស់នៅ (គ្មានសិទ្ធិបោះឆ្នោតឬឈរឈ្មោះសម្រាប់ការងារសាធារណៈ)។ រដ្ឋ មានកាតព្វកិច្ចការពារជនបរទេសទាំងនោះផងដែរ។ ទោះបីជាយ៉ាងនេះក្ដី ជនបរទេស ទទួលរងនូវការរើសអើង ឬការធ្វើទុក្ខបុកម្នេញ។

ដើម្បីការពារឆ្នាំ១៩៨៥ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីថ្លែងការណ៍ ស្ដីពី សិទ្ធិមនុស្សរបស់បុគ្គល ដែលមិនមានជាប្រជាពលរដ្ឋនៃប្រទេសដែលខ្លួនរស់នៅ (UN GA Declaration on the Human Rights of Individuals Who Are Not Nationals of the Country in Which They Live។ មាត្រា៥(១) បានចែងនូវសិទ្ធិដូចជា៖ សិទ្ធិសេរីភាពបុគ្គល សិទ្ធិជីវិតឯកជន សិទ្ធិទទួលបានការការពារស្មើភាពមុខតុលាការ សិទ្ធិអាពាហ៍ពិពាហ៍ សិទ្ធិសេរីភាពសាសនា សិទ្ធិរក្សាវប្បធម៌ឬ ភាសា សិទ្ធិផ្ទេរចំណូលទៅកាន់ប្រទេសរបស់ខ្លួន (James R. Lewis and Carl Skutsch, Human Rights Encyclopedia, Alien, 2001, p. 605)។

**ខ្លឹមសារបន្ថែម៖** ជនបរទេស មានច្រើនប្រភេទ ដែលរស់នៅខុសច្បាប់ ឬជាជនអន្តោប្រវេសន៍តាមច្បាប់។ ពួកគេ បានធ្វើដំណើរទៅក្រៅប្រទេស ដើម្បីជួបជុំរស់នៅក្នុងគ្រួសារ ឬដើម្បីការងារ។ អង្គការសហប្រជាជាតិ បានអនុម័តអនុសញ្ញា ស្ដីពី ការការពារជនទេសន្តប្រវេសន៍ ដោយផ្ដល់សិទ្ធិ ករណីកិច្ច និងការការពារពួកគេទាំងនោះ។